# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ៧៤៣/១៦ ក.អ.ជ-សសរ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៦

## សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសហគមន៍សន្សំប្រាក់

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** បង្កើតក្រុមការងារបច្ចេកទេសសហគមន៍សន្សំប្រាក់ អក្សរកាត់ « **ក.ក.ប.ស.ស** » (Technical Working Group on Community Savings - TWG-CS) ដើម្បីគាំទ្រសហគមន៍សន្សំប្រាក់របស់ប្រជាពលរដ្ឋដែលបាន និងកំពុងដំណើរការនៅតាមបណ្តារាជធានី ខេត្តគោលដៅ។

**ប្រការ ២.-** **ក.ក.ប.ស.ស** ជាក្រុមការងារអន្តរស្ថាប័នរវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូសហប្រតិបត្តិការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ (ក.អ.ជ) ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. លោកជំទាវ **ខេត ប៊ូរ៉ាមីន** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២. លោកបណ្ឌិត **ភាត សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ (ន.អ.ស.ជ) នៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក **ណី សាកល** | ប្រធាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ) | អនុប្រធាន |



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | | | |
|---|---|---|---|---|
| ៤. លោកស្រី | សុត | ស៊ីថុន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី | សមាជិកា |
| ៥. លោក | យ៉ាំ | ម៉េងស៊ាន | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦. លោក | លន់ | សំអុល | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យលើឯកសារ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៧. លោក | អ៊ិត | សំអាល់ | អនុប្រធាននាយកដ្ឋានសហគមន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. លោកស្រី | ឡាយ | វីរៈបុត្រ | អនុប្រធាននាយកដ្ឋាន អ.ស.ជ នៃ ក.អ.ជ | សមាជិកា |
| ៩. លោក | ជិន | រដ្ឋា | អនុប្រធាននាយកដ្ឋាន អ.ស.ជ នៃ ក.អ.ជ | សមាជិក |
| ១០. ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | | | | សមាជិកចំពោះកិច្ច |
| ១១.លោក | ទឹង | ទិដ្ឋានន្ទ | ប្រធានការិយាល័យមីក្រូហិរញ្ញវត្ថុ និងបរធនបាលកិច្ចហិរញ្ញវត្ថុ នៃ ស.ហ.វ | សមាជិក |
| ១២.លោក | ឡុច | វៀមវែត | ប្រធានការិយាល័យឥណទាន នៃ ក.អ.ជ | សមាជិក |
| ១៣.លោក | នី | សាភ័ត់ | អនុប្រធានការិ.រដ្ឋបាល និងហិរញ្ញវត្ថុ នៃ ក.អ.ជ | សមាជិក |
| ១៤.លោក | មុយ | សោភ័ណ | មន្ត្រី នៃ ក.អ.ជ | សមាជិក |
| ១៥.លោក | ម៉ៅ | មករា | មន្ត្រី នៃ ក.អ.ជ | សមាជិក |
| ១៦.លោក | ឈយ | សម្បត្តិ | មន្ត្រី នៃ ក.អ.ជ | សមាជិក |
| ១៧.លោក | គង់ | វីរៈ | មន្ត្រី នៃ ក.អ.ជ | សមាជិក |
| ១៨.លោក | ផៃ | ចិត្ត | តំណាងអង្គការអុកស្វាមកម្ពុជា | សមាជិក |
| ១៩.លោក | ជិញ | ភារៈ | តំណាងអង្គការអាគ្រីស៊ិត-អន្តរជាតិ | សមាជិក |
| ២០. លោកស្រី | អៀង | គីមស្រៀន | តំណាងអង្គការជីវិតថ្លៃថ្នូរ | សមាជិកា |
| ២១.លោក | នៅ | សត្ថា | តំណាងអង្គការប៉ាឌិក | សមាជិក |
| ២២.លោក | តែម | តុន | តំណាងអង្គការស្ទួនមូលនិធិ | សមាជិក |
| ២៣.លោកស្រី | តូច | ធរនាថ | តំណាងអង្គការ CWS | សមាជិកា |
| ២៤.លោកស្រី | ព្រុំ | ផលនីន | តំណាងអង្គការ អេ ស៊ី អា/ការីតាស អូស្ត្រាលី | សមាជិកា |
| ២៥.លោក | ទិត | សាវឿន | តំណាងអង្គការ អែហ្វ អេក កម្ពុជា | សមាជិក |
| ២៦.លោក | ឈុំ | ឆេងហេង | តំណាងអង្គការសាម៉ារីតាន់ ភឺស សង្គ្រោះអន្តរជាតិ | សមាជិក |
| ២៧.លោក | សន | ប៊ុនធឿន | តំណាងអង្គការសង្គ្រោះសត្វព្រៃ | សមាជិក |

**ប្រការ ៣.-** ក.គ.ប.ស.ស មានភារកិច្ចដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវ និងប្រមូលរាល់ព័ត៌មានសហគមន៍សន្សំប្រាក់
- រៀបចំផែនការមេ និងផែនការសកម្មភាពសម្រាប់កម្មវិធីសហគមន៍សន្សំប្រាក់

- រៀបចំគោលនយោបាយ គោលការណ៍ និងនីតិវិធីសម្រាប់គាំទ្រផ្នែកច្បាប់ និងបច្ចេកទេសនៃដំណើរការសហគមន៍សន្សំប្រាក់ ឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- ជ្រើសរើសខេត្តគោលដៅសម្រាប់អនុវត្តគម្រោងសាកល្បង
- ផ្សព្វផ្សាយ និងជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមក្នុងកម្មវិធីសហគមន៍សន្សំប្រាក់
- កៀរគរថវិកា និងទាក់ទាញឱ្យមានការចូលរួមគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធជាអាទិ៍ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល
- ផ្ញើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន

**ប្រការ ៤.-** ដំណើរការការងាររបស់ **គ.គ.ប.ស.ស** មានដូចខាងក្រោម ÷

- សមាជិក **គ.គ.ប.ស.ស** ត្រូវចូលរួមប្រជុំសាមញ្ញរៀងរាល់ ៣ ខែម្តង និងប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន **គ.គ.ប.ស.ស** តាមការចាំបាច់
- កិច្ចប្រជុំប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីហាសិបភាគរយ (៥០%) នៃចំនួនសមាជិកទាំងអស់
- ការអនុម័តត្រូវធ្វើឡើងដោយលើកដៃ និងដោយសម្លេងភាគច្រើននៃសមាជិកដែលបានចូលរួមប្រជុំ
- រាល់កិច្ចប្រជុំ ត្រូវមានកំណត់ហេតុ ឬរបាយការណ៍អង្គប្រជុំ និងត្រូវចម្លងជូនគ្រប់សមាជិក
- រាល់ការទំនាក់ទំនងរបស់ក្រុមការងារ ត្រូវអនុវត្តតាមរយៈលិខិតផ្លូវការ ឬសារអេឡិចត្រូនិច

**ប្រការ ៥.-** បង្កើតលេខាធិការដ្ឋាននៃ **គ.គ.ប.ស.ស** ដើម្បីសម្របសម្រួលដំណើរការការងារប្រចាំថ្ងៃរបស់ **គ.គ.ប.ស.ស** ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ។ សមាសភាពលេខាធិការដ្ឋាននៃ **គ.គ.ប.ស.ស** មានដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១.លោក | **ទី សារ៉ាត់** | អនុប្រធានការិ.រដ្ឋបាល និងហិរញ្ញវត្ថុ នៃ គ.អ.ជ | ប្រធាន |
| ២.លោក | **ម៉ៅ មករា** | មន្ត្រី នៃ គ.អ.ជ | អនុប្រធាន |
| ៣.លោក | **ឈ សម្បត្តិ** | មន្ត្រី នៃ គ.អ.ជ | សមាជិក |
| ៤.លោក | **គង់ វីរៈ** | មន្ត្រី នៃ គ.អ.ជ | សមាជិក |

**ប្រការ ៦.-** លេខាធិការដ្ឋាននៃ **គ.គ.ប.ស.ស** មានភារកិច្ចដូចខាងក្រោម ÷

- សម្របសម្រួលដំណើរការការងាររដ្ឋបាលប្រចាំថ្ងៃរបស់ **គ.គ.ប.ស.ស**
- រៀបចំផែនការការងារប្រចាំឆ្នាំ និងរបាយការណ៍វឌ្ឍនភាពការងាររបស់ **គ.គ.ប.ស.ស**

- សម្របសម្រួលរៀបចំរាល់កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗរបស់ **គ.គ.ប.ស.ស** ជាអាទិ៍ រៀបចំរបៀបវារៈ ឬកម្មវិធីនៃកិច្ចប្រជុំ រៀបចំ និងបញ្ជូនលិខិតអញ្ជើញ ធ្វើរបាយការណ៍ ឬកំណត់ហេតុប្រជុំ និងរៀបចំឯកសារ និងលិខិតស្នាមរដ្ឋបាលផ្សេងៗ
- ចែករំលែកព័ត៌មានជូនដល់គ្រប់សមាជិក សមាជិកា និងភាគីទាំងអស់ដែលពាក់ព័ន្ធនឹងកម្មវិធីសហគមន៍សន្សំប្រាក់

**ប្រការ ៧.-** រាល់សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ និងសាមីខ្លួន ដែលរាយនាមក្នុងប្រការ ២ និងប្រការ ៥ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

<u>កន្លែងទទួល</u> ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងកិច្ចការនារី
- អង្គការអុកស្វាមកម្ពុជា
- អង្គការអាគ្រីស៊ុត-អន្តរជាតិ
- អង្គការជីវិតថ្លៃថ្នូរ
- អង្គការប៉ាឌិក
- អង្គការស្វ័ធម្មលនិធិ
- អង្គការ CWS
- អង្គការ អេ ស៊ី អា/ការីតាស អូស្ត្រាលី
- អង្គការ អែហ្វ អេក កម្ពុជា
- អង្គការសាម៉ារីតាន់ ភឺស សង្គ្រោះអន្តរជាតិ
- អង្គការសង្គ្រោះសត្វព្រៃ

"*ដើម្បីជូនជ្រាប*"
- ដូចប្រការ ២ និងប្រការ ៥

"*ដើម្បីអនុវត្ត*"
- ឯកសារ-កាលប្បវត្តិ